ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ:១៣៧៤ ក ១១ហ

# កំណត់ហេតុ

ថ្ងៃអង្គារ បួនរោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ពីរពាន់ប្រាំរយប្រាំពីរ ត្រូវនឹងថ្ងៃទីពីរ ខែតុលា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងពីរនិងសាមសិបនាទីរសៀល នៅសាលប្រជុំខេត្តរតនគិរី ទីស្តីការក្រសួងមហាផ្ទៃ បានបើកកិច្ចប្រជុំ ដើម្បីបន្តពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សារណៈ នៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា ក្រោមអធិបតីភាព ឯកឧត្តម **អ៊ូច ចាន់ណូរ៉ា** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ។

សមាសភាពអញ្ជើញចូលរួម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ី សុខឃី | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ចាង រ៉ាស៊ី | អនុប្រធានក្រុមប្រឹក្សានីតិកម្ម |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ស្វាយ ចាន់ដា | អគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានមនុស្ស |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ឹម ប្រណិតា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៥-ឯកឧត្តម | ស៊ី ថារិន | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក | សំ បួរ | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៧-ឯកឧត្តម | សុខ លីនណា | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៨-ឯកឧត្តម ឧត្តមសេនីយ៍ទោ | សាង សុផន | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ |
| ៩-លោកជំទាវ ឧត្តមសេនីយ៍ទោ | រ៉ែន សិរីលក្ខណា | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| ១០-ឯកឧត្តម ឧត្តមសេនីយ៍ឯក | សិទ្ធ ម៉ីនធី | អនុប្រធានសេនាធិការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១១-លោក ឧត្តមសេនីយ៍ត្រី | ខេង ប៉ូលីដា | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន |
| ១២-លោក ឧត្តមសេនីយ៍ត្រី | ឈឹម សម្បត្តិ | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៣-លោក | ថង វីឫទ្ធិ | សមាជិក នៃក្រុមប្រឹក្សានីតិកម្ម |
| ១៤-លោក វរសេនីយ៍ឯក | ឱម ទិត្យសត្យា | សមាជិក នៃក្រុមប្រឹក្សានីតិកម្ម |
| ១៥-លោកស្រី | ព្រុំ សួនសត្យា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន |
| ១៦-លោក វរសេនីយ៍ត្រី | ជុន ស៊ីនលី | នាយផ្នែក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៧-លោក វរសេនីយ៍ទោ | សេភ ឡង់ឌី | អនុប្រធាននាយកដ្ឋានសរុប និងស្ថិតិ និងជាលេខាកត់ត្រា |
| ១៨-លោក អនុសេនីយ៍ឯក | ហុង តិចឈៀង | នាយផ្នែក នៃនាយកដ្ឋានសរុបនិងស្ថិតិ និងជាលេខាកត់ត្រា |

១៩-លោក អនុសេនីយ៍ទោ **មិន តិរុទ្ធ** នាយរងផ្នែក នៃនាយកដ្ឋានសរុបនិងស្ថិតិ និងជាលេខាកត់ត្រា

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **អ៊ូច ចាន់ណូរ៉ា** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាប្រធានអង្គប្រជុំ បានមានប្រសាសន៍ស្វាគមន៍ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលជាសមាជិក-សមាជិកានៃអង្គប្រជុំ និងបានគូសបញ្ជាក់ថា កិច្ចប្រជុំថ្ងៃនេះ គឺជាកិច្ចប្រជុំលើកទី២ ដើម្បីបន្តពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សារណៈ នៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា។

មុននឹងឈានចូលដល់កិច្ចប្រជុំបន្ត ខ្ញុំសូមរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃកិច្ចប្រជុំលើកទី១ កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣កន្លងមក ក្នុងនោះ អង្គប្រជុំបានពិនិត្យ ពិភាក្សាលើសេចក្តីព្រាងខាងលើនេះយ៉ាងយកចិត្តទុកដាក់ និងមានការទទួលខុសត្រូវខ្ពស់ អង្គប្រជុំបានឯកភាពលើខ្លឹមសារពីមាត្រា១ ដល់ត្រឹមមាត្រា៥ នៃសេចក្តីព្រាងនេះ។ **ឯកឧត្តមប្រធានអង្គប្រជុំ** បានអនុញ្ញាតឱ្យ **លោក ឧត្តមសេនីយ៍ត្រី ខេង ម៉ូលីដា** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន អានខ្លឹមសារនៃសេចក្តីព្រាងជាភាសាអង់គ្លេស និងបកប្រែទៅជាភាសាខ្មែរ ត្រង់មាត្រា៥ លើចំណុចទី១ ទី២ និងទី៣ ម្តងទៀតជូនអង្គប្រជុំជ្រាប។

តបកទៀត អង្គប្រជុំបានយកខ្លឹមសារត្រង់មាត្រា៥ លើចំណុចទី១ ទី២ និងទី៣ មកពិនិត្យ ពិភាក្សា និងដាក់ផ្លូវមតិយោបល់អង្គប្រជុំ...៖

**<u>មាត្រា៥</u>**

ចំពោះខ្លឹមសារ ត្រង់ចំណុចទី១ ទី២ និងទី៣ ក្នុងមាត្រា៥ នៃសេចក្តីព្រាងនេះ អង្គប្រជុំបានឯកភាពគ្នាលុបចោលពាក្យ *“ Will ”* ចេញ និងផ្លាស់ប្តូរទៅយកពាក្យ *“ Shall ”* វិញ ដោយសារពាក្យ *“ Shall ”* នេះ គឺបានបញ្ជាក់ពីសកម្មភាពអនុវត្តច្បាប់ជាក់លាក់ និងមានន័យគ្រប់គ្រាន់សម្រាប់បញ្ជាក់ន័យនៅក្នុងសេចក្តីព្រាងនេះ គឺ “ *អនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា* ” ។

រីឯចំណុចទី៤ថ្មី របស់ភាគីសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា បានធ្វើការស្នើសុំបន្ថែមចំណុចទី៤ថ្មី មួយទៀត ដើម្បីងាយស្រួលក្នុងការសម្របសម្រួលលើការអនុវត្តការងារនៅក្នុងសេចក្តីព្រាងនេះឱ្យកាន់តែមានប្រសិទ្ធភាព **ឯកឧត្តមប្រធានអង្គប្រជុំ** បានយកសំណើត្រង់ចំណុចទី៤ថ្មីនេះ ដាក់ជូនអង្គប្រជុំធ្វើការពិនិត្យ ពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ខ្ពស់ ហើយអង្គប្រជុំបានឯកភាពគ្នាលើខ្លឹមសារនេះទាំងស្រុង។

**<u>មាត្រា៦</u>**

-មាត្រា៦ ពាក់ព័ន្ធនឹងខ្លឹមសារចំណងជើង អង្គប្រជុំបានពិនិត្យ ពិភាក្សា និងយល់ឃើញថា គួរកែសម្រួលទៅពាក្យ ថា ***“ យន្តការសហប្រតិបត្តិការ Cooperation Mechanism ” ។***

**-មាត្រា៦ ចំណុចទី១ ត្រង់ a) និង b) អង្គប្រជុំបានស្នើដាក់ឃ្លាជាពីរជម្រើស ៖**

a). *For the Royal Government of Cambodia: Ministry of Interior/*

*For the Ministry of Interior of the Kingdom of Cambodia: The General Secretariat*

b) *For the Government of the Federal Republic of Nigeria: Ministry of Interior/*

*For the Ministry of Interior of the Federal Republic of Nigeria: ...........*

ប៉ុន្តែត្រង់ចំណុចទាំងពីរខាងលើនេះ អង្គប្រជុំពុំទាន់សម្រេចយ៉ាងណានៅឡើយទេ ដោយដាក់ហែឡាយពណ៌លឿងរក្សាទុកសិន។

-មាត្រា៦ ចំណុចទី២ អង្គប្រជុំបានឯកភាពគ្នាលើខ្លឹមសារនេះទាំងស្រុង។

-មាត្រា៦ ចំណុចទី៣ អង្គប្រជុំបានឯកភាពគ្នាលើខ្លឹមសារនេះទាំងស្រុង។

ក្រោយពីបានឆ្លងមតិយោបល់ វែកញែកគ្នាយ៉ាងផុសផុល ពិនិត្យ ពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់រួចមក **ឯកឧត្តម ប្រធានអង្គប្រជុំ** បានដាក់ចេញនូវគោលការណ៍ និងសំណូមពរ រួមមាន ដូចខាងក្រោម ៖

១-ស្នើឱ្យមន្ត្រីជំនាញ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន ជួយបកប្រែអត្ថបទភាសាអង់គ្លេសនៃសេចក្តីព្រាងនេះ ចំពោះចំណុចមាត្រាដែលអង្គប្រជុំមិនទាន់បានពិភាក្សា ឱ្យទៅជាភាសាខ្មែរ សម្រាប់ដាក់ជូនអង្គប្រជុំនៅកិច្ចប្រជុំបន្ទាប់ ដើម្បីងាយស្រួលយល់ពីខ្លឹមសារ និងគោលបំណងច្បាស់លាស់តាមមាត្រានីមួយៗ នៃសេចក្តីព្រាងអនុស្សរណៈនេះ។

២-នៅពេលក្រុមការងារពិនិត្យ និងកែសម្រួលរួចហើយ ក្រុមការងារបច្ចេកទេសដែលមានតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ គួររៀបចំឱ្យមានជំនួបពិភាក្សាជាមួយភាគីសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ាមួយជំហានសិន ដើម្បីចង់ដឹងពីគោលជំហរ និងគោលបំណងផ្ទាល់របស់គាត់ ថាតើគាត់ចង់បានតម្រូវការដាក់លាក់អ្វីខ្លះដែលត្រូវចែងក្នុងសេចក្តីព្រាងនេះ មុននឹងឈានដល់ការចុះហត្ថលេខាលើ MOU។

៣-ចំពោះមាត្រាដែលនៅសេសសល់ចាប់ពីមាត្រា៧តទៅ អង្គប្រជុំនឹងរៀបចំដាក់កម្មវិធីប្រជុំឆ្លងមតិយោបល់ ពិនិត្យ ពិភាក្សា នៅសប្តាហ៍ក្រោយបន្តទៀត។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងប្រាំល្ងាច នាថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣

**លេខាកត់ត្រា**

វរសេនីយ៍ទោ **សេក ឡង់ឌី**

**បានឃើញ និងឯកភាព**

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១២ខែតុលា ឆ្នាំ២០២៣

**ប្រធានអង្គប្រជុំ**

**អ៊ុច ចាន់ណារ៉ា**